ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ: ៥៨៩ -ជ-ក្រ៦
ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ៦២៥៨
ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
-ស៊ើបសួរលេខ៥១៨៥
ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩
-ជំនុំជម្រះលេខ៥៣០
ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

សាលក្រម
នាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០
វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក នៅសាលសវនាការទី៥
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជី

លោកស្រី [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៥៤២ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] រតនា ហៅ តុល ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅមុនពេលឃាត់ខ្លួននៅភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សារិទ្ធ "រស់" ម្តាយឈ្មោះ [redacted] អេង "រស់" ជាន៏តិជន ធ្លាប់ជាប់មណ្ឌលបន្សាបគ្រឿងញៀនឱកាសខ្ចីអស់រយៈពេល១៥ខែ ។ (ប៉ុន្តែតាមដីកាបង្គាប់លេខ ១០២៦២ "ព"ដ.ឃ.ដ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩)

២. ឈ្មោះ [redacted] ខឿន ហៅ ភា ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើត នៅ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅផ្ទះវល់ ភូមិគ្រាលគោ សង្កាត់គីឡូម៉ែត្រ លេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សេង "រស់" ម្តាយឈ្មោះ [redacted] សុវណ្ណ "រស់" ជាអន៏តិជន ធ្លាប់ជាប់មណ្ឌលបន្សាបគ្រឿងញៀនឱកាសខ្ចីអស់រយៈពេល០៦ខែ ។ (ប៉ុន្តែតាមដីកាបង្គាប់លេខ ១០២៦១ "ព"ដ.ឃ.ដ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩)

លោកមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ខឿន ហៅ ភា ។

ជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់យីហោ ធ្វីន បន្ទប់លេខ ១០៧ ផ្លូវបេតុង ភូមិវាលចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង០០ នាទី តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

អំពីអង្គហេតុ

តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាដំណោះស្រាយបញ្ហានសំណុំរឿងទៅជំនុំជម្រះបានឈើកឡើងនូវអង្គហេតុនៃរឿងក្តីនេះថា៖ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី នៅចំណុចផ្ទះសំណាក់យីហោធ្វីន បន្ទប់លេខ១០៧ ផ្លូវបេតុង ភូមិវាលចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលគោកឃ្លាង បានធ្វើការឃាត់ខ្លួនជនជាប់ចោទចំនួន០២នាក់រួមមានឈ្មោះ [redacted] រតនា ហៅ តុល ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] វឿន ហៅ កា ភេទស្រី អាយុ១៧ឆ្នាំ ជនជាតិខ្មែរ បានធ្វើការឆែកឆេររកឃើញថ្នាំញៀនចំនួន ០៣ កញ្ចប់ធំល្មមទុកក្នុងកាបូបស្ពាយចំហៀងរបស់ឈ្មោះ [redacted] វឿន ហៅ កា ហើយជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល បានសារភាពថាថ្នាំញៀននោះគឺខ្លួនបានចូល លុយគ្នាជាមួយឈ្មោះ ភា ភេទប្រុស អាយុប្រហែល ២៩ឆ្នាំ ជនជាតិខ្មែរ ក្នុងម្នាក់ៗ ២០០.០០០ (ម្ភៃម៉ឺន) រៀល ទៅទិញថ្នាំញៀនពីមនុស្សស្រីម្នាក់មិនឈ្មោះនៅម្តុំទួលពង្របានចំនួន០១កញ្ចប់ធំបន្ទាប់មកឈ្មោះ [redacted] រតនា ហៅ តុល បានយកមកវិលកបានចំនួន០៣កញ្ចប់ដើម្បីទុកលក់ឱ្យម៉ូយបន្ត ។

-បានឃើញ ៖ របាយការណ៍សំយោគលេខ ៤៣៨/១៩ រ.ប.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ។

-បានឃើញ ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤២៥៥ អ.យ.ឆ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ៖ ដីកាសន្និដ្ឋានស្តាពរលេខ ១១៦ អ.យ.ឆ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៥ “ព” ដ.ដ ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល បានឆ្លើយថា៖ ខ្ញុំបាទត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅក្នុងផ្ទះសំណាក់យីហោធ្វីន រួមជាមួយឈ្មោះ [redacted] វឿន ហៅ កា និងគ្រឿងញៀនចំនួន០៣កញ្ចប់ ។ នៅថ្ងៃមុនពេលសមត្ថកិច្ចឃាត់ខ្លួន ខ្ញុំបាទនិងឈ្មោះ ភា បាននាំគ្នាទៅទិញថ្នាំញៀននៅស្តុបទួលពង្រប្រហែលម៉ោង៩ព្រឹកដោយចូលលុយគ្នាទិញម្នាក់ ៥០ (ហាសិប) ដុល្លាសហរដ្ឋអាមេរិក ។ ក្រោយពីទិញថ្នាំញៀនរួច ឈ្មោះ ភា បានទុកគ្រឿងញៀននៅជាប់នឹងខ្លួនហើយខ្ញុំបាទបានយកគ្រឿងញៀនទៅផ្ទះសំណាក់យីហោធ្វីន ចំណែកឈ្មោះ [redacted] វឿន ក៏បាន មកដល់ផ្ទះសំណាក់ផងដែរ ដោយខ្ញុំបាទបានហៅមកប្រើប្រាស់គ្រឿងញៀន ចំណែកឈ្មោះ ភា បានគេទូរស័ព្ទមក ខ្ញុំបាទថាឱ្យទុកគ្រឿងញៀននៅនោះសិនទៅចាំគេមកដល់ចាំគេជាអ្នកចាត់ចែង ។ ពេលកន្លងមកខ្ញុំបាទធ្លាប់ ទិញគ្រឿងញៀនឱ្យគេផងដែរដើម្បីជក់ជាមួយគ្នា ។ ចំពោះសង្សាររបស់ខ្ញុំឈ្មោះ [redacted] វឿន

ធ្លាប់ជក់គ្រឿងញៀនជាមួយ ខ្ញុំបាទពាដងមកហើយ ហើយនៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនគឺឈ្មោះ [redacted] វឿន មិនដឹងថាខ្ញុំមានគ្រឿងញៀនច្រើនដូច្នេះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា បានឆ្លើយថា ៖ នាងខ្ញុំត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅក្នុងផ្ទះសំណាក់ឃីហោធ្វីនរួមជាមួយឈ្មោះ [redacted] រតនា ហៅ តុល ដែលជាសង្សាររបស់ខ្ញុំនិងគ្រឿងញៀនចំនួន០៣កញ្ចប់ ។ នៅមុនថ្ងៃសមត្ថកិច្ចឃាត់ខ្លួន នាងខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀនជាមួយសង្សាររបស់ខ្ញុំឈ្មោះ [redacted] រតនា បីទៅបួនដងដែរនៅបន្ទប់ផ្ទះជួល បន្ទាប់មកប្តូរទៅជួលបន្ទប់នៅផ្ទះសំណាក់ឃីហោធ្វីនវិញ ដោយនាងខ្ញុំនិងឈ្មោះ រតនា ជាសង្សាររបស់នាងខ្ញុំប្រើប្រាស់គ្រឿងញៀនក្នុងផ្ទះសំណាក់ឃីហោធ្វីននេះក៏ត្រូវសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្តង ។ នាងខ្ញុំមិនដឹងថា រតនា ទិញគ្រឿងញៀនមកពីណាទេហើយក៏មិនដឹងថា រតនា មានគ្រឿងញៀនច្រើនបែបនេះដែរ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា បានបញ្ជាក់ថា៖ ផ្អែកតាមចម្លើយជនជាប់ចោទគ្រប់ដំណាក់កាលឃើញថាគាត់បានឆ្លើយបានឆ្លើយសារភាពពីកំហុសរបស់ខ្លួន ហើយបានចូលរួមបង្ហាញខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី ពុំមានការគេចវេចនោះទេ ។ ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្លួនជាអនីតិជន គប្បីតុលាការពិចារណាបន្ធូបន្ថយទោស ដល់កូនក្តីខ្ញុំផង ។

-ក្រឡាបញ្ជីអានកំណត់ហេតុលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២១៥៣៤/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍គ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថាសំណាកគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (អាយ ម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧២,៤៩% (ចិតសិបពីរក្បៀសសែសិបប្រាំបួន) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

<u>សេចក្តីសន្និដ្ឋានប្តឹងសុំយោបល់របស់តំណាងអយ្យការ</u>

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការជនជាប់ចោទបានឆ្លើយថាខ្លួនពិតជាបានធ្វើអំពើដែលបានកើតឡើងកន្លងមកដូចការរៀបរាប់មែន ដែលបញ្ជាក់ថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ច្រាកដមែន ។

ដូច្នេះតំណាងអយ្យការ សុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ១៦៩ អ.ឃ.ធ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចទៅតាមច្បាប់ ។

<u>សម្តីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល និងឈ្មោះ [redacted] វឿន ហៅ កា បាននិយាយសំដីចុងក្រោយបង្អស់ថា: ខ្លួនស្នើសុំឱ្យតុលាការបន្ធូបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

Scanned with CamScanner

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១/. ដីកាសន្និដ្ឋានស្តាពរលេខ ១១៦ អ.ឃ.ធ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៥ "ព" ដ.ដ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លើឈ្មោះ ផង់ រតនា និងឈ្មោះ [redacted] វឿន ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ឃីហោធ្វីន បន្ទប់លេខ ១០៧ ផ្លូវបេតុង ភូមិរោងចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង០០ នាទី តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/. តាមអង្គហេតុដែលបានកើតឡើង និងចម្លើយរបស់ជនជាប់ចោទ ជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានា ឃើញថាមានភាពស៊ីសង្វាក់គ្នា អាចបង្ហាញឱ្យឃើញថាជនជាប់ចោទទាំងពីរពិតជាបានប្រព្រឹត្តអំពើទុច្ចរិត ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/. អំពើ និងសកម្មភាពរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈជាពិសេស ប៉ះពាល់ដល់សុខភាពអ្នកដទៃយ៉ាងធ្ងន់ធ្ងរ និងប៉ះពាល់ដល់សីលធម៌ប្រសាទ អំពើនេះគឺជាអំពើល្មើសដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤/. ពេលធ្វើសកម្មភាពជនជាប់ចោទឈ្មោះ [redacted] រតនា មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ប្រព្រឹត្តអំពើល្មើសច្បាប់រហូតបានសម្រេចបំណងរបស់ខ្លួន ហើយជានីតិជន ដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៥/. សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា ដែលជាអនីតិជន ស្ថិតក្នុងស្ថានភាពដែលពុំទាន់មានស្មារតីពេញលេញ និងសមត្ថភាពក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន និងការវិនិច្ឆ័យផងដែរ ម្យ៉ាងវិញទៀត ស្របតាមស្មារតីមាត្រា១៦១ ចំណុច១ នៃក្រមព្រហ្មទណ្ឌ អនីតិជនត្រូវទទួលបាននូវស្ថានសម្រាលក្នុងលក្ខខណ្ឌដើម្បីជាប្រយោជន៍ដល់អនីតិជនក្នុងការអនុវត្តទោសផងដែរ តាមមាត្រា ៥ និងមាត្រា ៧ នៃច្បាប់ស្តីអំពីយុត្តិធម៌អនីតិជន ។

៦/. តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ២១៥៣៥/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍គ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថា សំណាកគ្រឿងញៀន

ប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (អាយ ម៉ាទីកកក) ដែលមានកម្រិតភាពសុទ្ធ ៧២,៤៩% (ចិតសិបពីរក្បៀសសែសិបប្រាំបួន) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧/. តាមការគណនាអំពីភាពសុទ្ធនៃមេតំហ្វេតាមីន របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល និង ជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា មានទម្ងន់សរុប ៥,១៨ (ប្រាំក្បៀសដប់ប្រាំបី) ក្រាម ដែល {(៥,១៨ × ៧២,៤៩)/១០០} = ៣,៧៥ ក្រាម ឃើញថាសារធាតុសុទ្ធចំនួន ៣,៧៥ (បីក្បៀសចិតសិបប្រាំ) ក្រាម ។

ជាលទ្ធផល ៣, ៧៥ (បីក្បៀសចិតសិបប្រាំ) ក្រាម គឺស្ថិតក្នុងតារាងទី២ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.000.000 (បួនលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ហេតុនេះ គប្បីតុលាការពិចារណាអំពីការផ្តន្ទាទោសសម្រាប់ជនជាប់ចោទទាំងពីរនេះ ។

៨/. គ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទ គឺជាគ្រឿងញៀនដែលបានធ្វើសកម្មភាពជួញដូរដូច្នេះគប្បីតុលាការពិចារណាសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងពីរនេះឲ្យទទួលទោសពន្ធនាគារ ដោយផ្អែកលើសារធាតុសុទ្ធនៃគ្រឿងញៀននេះ ។

៩/. តំណាងអយ្យការបានសន្និដ្ឋានថា៖ ស្នើសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ១១៦ ចុះថ្ងៃទី១0 ខែមករា ឆ្នាំ២0២0 ទុកនៅដដែល គប្បីតុលាការលើមកពិចារណា ។

១0/. មានភស្តុតាងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា ភេទស្រី អាយុ១៧ ជនជាតិខ្មែរ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ឃីហោធ្វីន បន្តប់លេខ ១0៧ ផ្លូវបេតុង ភូមិរោងចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី0៨ ខែកញ្ញា ឆ្នាំ២0១៩ វេលាម៉ោង ១៤ និង00 នាទី តាមបញ្ញត្តិមាត្រា ៤0 នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១/. វត្ថុចាប់យកដែលមានក្នុងកំណត់ហេតុទទួលយកវត្ថុចាប់យក (១) លេខ ២៨៧៩ រ.ន.ត ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២0១៩ មានដូចជា៖ ស្រោមសំបុត្រពណ៌សបិទជិតសរសេរថា ក្រាមពណ៌សថ្លា ដែលមានតម្រុយជាសារធាតុញៀន ប្រភេទមេតំហ្វេតាមីន មានទម្ងន់ ៥,១៨ (ប្រាំក្បៀសដប់ប្រាំបី) ក្រាម ដែលមានស្នាមមេដៃជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ តុល និងហត្ថលេខាសមាសភាពចូលរួម ។

វត្ថុចាប់យកនេះ ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស ស្របតាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

<u>ហេតុផ្តួចផ្តើមនិងបញ្ជរសេចក្តី</u>

១/. ផ្តន្ទាទោស ឈ្មោះ [redacted]រតនា ហៅ តុល ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់យីហោធ្វីន បន្ទប់លេខ ១០៧ ផ្លូវបេតុង ភូមិរោងចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង០០ នាទី តាមបញ្ជត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/. ផ្តន្ទាទោស ឈ្មោះ [redacted]វឿន ហៅ កា ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់យីហោធ្វីន បន្ទប់លេខ ១០៧ ផ្លូវបេតុង ភូមិរោងចក្រ១ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង០០ នាទី តាមបញ្ជត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/. ឥស្សាច់យកទ គ្រឿងញៀនប្រភេទក្រាមពណ៌សថ្លា ឈ្មោះ **មេតំហ្វេតាមីន** (ហៅកាត់ថា ម៉ាទីកកក ឬICE) ទម្ងន់ ៥,១៨ (ប្រាំក្បៀសដប់ប្រាំបី) ក្រាម ត្រូវរឹបអូសបំផ្លាញចោលតាមមាត្រា៨៤ ចំនុចពា និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]រតនា ហៅ តុល និងជនជាប់ចោទឈ្មោះ [redacted] វឿន ហៅ កា ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ព្រះរាជអាជ្ញាសហនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០
ព្រះរាជអាជ្ញា

[redacted]